# ចិត្តវគ្គ ទី ៣

## ១. រឿងព្រះមេឃិយត្ថេរៈ

*(ពោលដោយការហ្វឹកហ្វាត់ចិត្ត)*

[១៣] ព្រះសាស្តា កាលប្រថាប់នៅលើភ្នំឈ្មោះចាលិកា ទ្រង់ប្រារព្ធព្រះមេឃិយៈត្រាស់ព្រះធម្មទេសនានេះថា ផន្ទនំ ចបលំ ចិត្តំ (ចិត្តដែលញាប់ញ័រឃ្លេងឃ្លោង) ជាដើម ។

មេឃិយៈទាំងអស់ បណ្ឌិតគប្បី (សំដែង) ឲ្យពិស្តារដើម្បីឲ្យរឿងនៃព្រះមេឃិយត្ថេរៈនោះជាក់ច្បាស់ ។ ក៏ព្រះសាស្តាទ្រង់ហៅព្រះមេឃិយៈដែលលោកមិនអាចប្រកបសេចក្តីព្យាយាមក្នុងអម្ពវ័ននោះបាន ព្រោះលោកត្រូវវិតក្កៈ ៣ គ្របសង្កត់ ត្រឡប់មកហើយ ទើបត្រាស់ថា មេឃិយៈ អ្នកលះបង់តថាគតឲ្យនៅម្នាក់ឯង ហើយស្រែកយំថា មេឃិយៈ យើងនៅតែឯងៗ អ្នកចូររង់ចាំ ហូតដល់ភិក្ខុដទៃទៀតប្រាកដ ដូច្នេះ (ឈ្មោះថា) ធ្វើកម្មដ៏ធ្ងន់ក្រៃលែង ។ ដែលឈ្មោះថា ភិក្ខុជាអ្នកធ្លាក់នៅក្នុងអំណាចរបស់ចិត្ត

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.033_att

យ៉ាងនេះ មិនគួរ ឈ្មោះថា ចិត្តជាធម្មជាតិ (ស៊ុះទៅ) រហ័ស ការញ៉ាំងចិត្តនោះឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន រមែងគួរ ដូច្នេះ ទើបទ្រង់បានភាសិតព្រះគាថា ២ គាថានេះថា ៖

ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ
ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ ។
វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ
បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ ។

អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ យេ៉ងយោ៉ង រក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បាន ដូចអ្នកធ្វើព្រួញ ពត់ព្រួញឲ្យត្រង់ ។ ចិត្តនេះដែលបុគ្គលលើកឡើងចាកអាល័យ គឺ កាមគុណ ៥ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្ដៈជាទីនៅនៃមារ រមែងញាប់ញ័រ ដូចត្រីដែលគេលើកឡើងចាកទឹកទៅ គឺ ទឹក បោះទៅលើគោក ដូច្នោះឯង ។

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.033_att

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.033_att

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា ផន្ទនំ (ញាប់ញ័រ) គឺ ញាប់ញ័រនៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ។ បទថា ចបលំ (ឃ្លេងឃ្លោង) បានដល់ មិនតាំងនៅក្នុងអារម្មណ៍តែមួយបាន ដូចទារកក្នុងផ្ទះ នៅមិនស្ងៀមដោយឥរិយាបថណាមួយដូច្នោះ ទើបឈ្មោះថា ឃ្លេងឃ្លោង ។ បទថា ចិត្តំ (ចិត្ត) បានដល់ វិញ្ញាណ ។ ក៏វិញ្ញាណនោះ ព្រះមានព្រះភាគត្រាស់ហៅថា ចិត្ត ព្រោះជាធម្មជាតិវិចិត្រ ដោយភូមិ វត្ថុអារម្មណ៍ និងវិថីចិត្ត មានកិរិយាចិត្តជាដើម ។ បទថា ទុរក្ខំ (រក្សាបានលំបាក) បានដល់ ឈ្មោះថា ដែលបុគ្គលរក្សាបានដោយលំបាក ព្រោះតាំងទុកបានលំបាកក្នុងអារម្មណ៍ដែលជាទីសប្បាយណាមួយនោះឯង ។ បទថា ទុន្និវារយំ (ហាមឃាត់បានដោយលំបាក) បានដល់ ឈ្មោះថា ដែលបុគ្គលហាមបានលំបាក ព្រោះជាធម្មជាតិរក្សាបានដោយលំបាក ដើម្បីនឹងហាម (ភគាំង) ចិត្តដែលទៅកាន់វិសភាគារម្មណ៍ ។ បទថា ឧសុការោវ តេជនំ (ដូចអ្នកពត់ព្រួញ ពត់ព្រួញឲ្យត្រង់ ដូច្នោះ) សេចក្តីថា នាយជាងព្រួញនាំយកកំណាត់ឈើមួយ

កំណាត់មកអំពីព្រៃហើយ បកសំបកចេញ លាបដោយទឹកបាយ និងប្រេង រោលត្រង់ក្បៀងផ្សែងភ្លើង កាត់ត្រង់ចម្លាមឈើ ធ្វើឲ្យបាត់កោង គឺ ឲ្យត្រង់ ឲ្យជារបស់គួរដល់ការបាញ់រោមទ្រាយបាន ។ ក៏គ្រាធ្វើហើយ ទើបសំដែងសិល្បៈចំពោះព្រះរាជា និងរាជមហាមាត្យ រមែងបានសក្ការៈ និងសេចក្ដីរាប់អានដ៏ច្រើន យ៉ាងណា បុរសអ្នកមានបញ្ញា គឺ បណ្ឌិត បានដល់ អ្នកដ៏ងច្បាស់ ក៏ដូច្នោះដូចគ្នា (គឺ) ធ្វើចិត្តនេះ ដែលមានសភាពញាប់ញ័រជាដើម ឲ្យអស់សំបក គឺ ឲ្យប្រាសចាកកិលេសដែលគ្រោតគ្រាត ដោយអំណាចធុតង្គ និងការនៅព្រៃ ហើយលាបដោយជ័រ គឺ សទ្ធា រោលដោយសេចក្ដីព្យាយាមដែលប្រព្រឹត្តទៅផ្លូវកាយ និងផ្លូវចិត្ត កាត់ត្រង់ចម្លាម គឺ សមថៈ និងវិបស្សនា ធ្វើឲ្យត្រង់ បានដល់ ឲ្យអស់អំណាច លុះធ្វើហើយ ពិចារណាសង្ខារទាំងឡាយ ទម្លាយគំនរអវិជ្ជាធំបានហើយ ធ្វើគុណវិសេសនេះ គឺ វិជ្ជា ៣[១] អភិញ្ញា ៦[២] លោកុត្តរធម៌ ៩[៣] ឲ្យនៅក្នុងទីក្នុងកណ្ដាប់ដៃរបស់

---

១-វិជ្ជា ៣ = បុព្វេនិវាសានុស្សតិវិជ្ជា ១ , ចុតូបបាតវិជ្ជា ១ , អាសវក្ខយវិជ្ជា ១ ។ ២-អភិញ្ញា ៦ = ឥទ្ធិវិធី ១ , ទិព្វសោត ១ , ចេតោបរិយញ្ញាណ ១ , បុព្វេនិវាសានុស្សតិញ្ញាណ ១ , ទិព្វចក្ខុ ១ , អាសវក្ខយញ្ញាណ ១ ។ ៣-លោកុត្តរធម៌ ៩ = មគ្គ ៤ ផល ៤ និព្វាន ១ ។

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.033_att

ខ្លួន រមែងបានជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ។

បទថា វារិជោវ (ដូចត្រី) បានដល់ ដូចមច្ឆា ។ បទថា ថលេ ខិត្តោ (ត្រូវ...បោះទៅលើគោក) បានដល់ ត្រូវបោះទៅលើគោកដោយដៃ ឬជើង ឬដោយគ្រឿងចាប់ មានសំណាញ់ជាដើមយ៉ាងណាមួយ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា ឱកមោកតឧព្ភតោ (ដែលត្រូវលើកឡើងអំពីទីនៅ គឺ ទឹក) (ដូចតទៅនេះ) ទឹក ឈ្មោះថា ឱកៈ ក្នុងបទនេះថា ឱកបុណ្ណេហិ ចីវរេហិ (ភិក្ខុអ្នកក្រុងបាឋា មានចីវរទទឹកដោយទឹក) ។ អាល័យ ឈ្មោះថា ឱកៈ ក្នុងបទនេះថា ឱកំ បហាយ អនិកេតសារី (មុនីលះបង់អាល័យហើយមិនជាប់នៅ) ។ សូម្បីបទទាំងពីរ ក៏រមែងបានក្នុងបាទព្រះគាថានេះ ។ ក្នុងបទថា ឱកមោកតោ នេះ មានសេចក្តីយ៉ាងនេះថា ចាកទីនៅ គឺ ទឹក គឺ ចាកទីអាល័យ គឺ ទឹក ។ បទថា ឧព្ភតោ (លើកឡើង) បានដល់ ត្រូវលើកឡើងហើយ ។ បទថា បរិផន្ទតិទំ ចិត្តំ (ចិត្តនេះរមែងញាប់ញ័រ) សេចក្តីថា ចិត្តនេះ គឺ ដែលត្រេកអរហើយក្នុងអាល័យ គឺ កាមគុណ ៥ ដែលព្រះយោគាវចរលើកឡើងហើយអំពីអាល័យ គឺ កាមគុណ ៥ នោះ

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.033_att

បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដុតដោយសេចក្តីព្យាយាមដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងផ្លូវចិត្ត ដើម្បីលះវដ្តៈ ពោលគឺ អន្ទាក់មារ រមែងញាប់ញ័រ គឺ មិនអាចតាំងនៅក្នុងវិបស្សនាកម្មដ្ឋាននោះបាន ដូចជាត្រីដែលត្រូវលើកឡើងចាកទីអាល័យ បោះទៅលើគោក កាលមិនបានទឹក រមែងញាប់ញ័រដូច្នោះ ។ ចំណែកបុគ្គលអ្នកមានបញ្ញា មិនដាក់ធុរៈ រមែងធ្វើចិត្តនោះឲ្យត្រង់ គឺ ឲ្យគួរដល់ការងារ ដោយន័យដូចពោលហើយនោះឯង ។

ន័យម្យ៉ាងទៀត ចិត្តនេះ ដែលលះបង់អន្ទាក់មារ គឺ កិលេសវដ្តៈមិនបាន ហើយតាំងនៅ រមែងញាប់ញ័រដូចត្រីនោះដូច្នោះ ព្រោះដូច្នោះ ព្រះយោគាវចរគប្បីលះបង់អន្ទាក់មារចេញ គឺ គួរលះបង់អន្ទាក់មារ ពោលគឺកិលេសវដ្តៈដែលជាហេតុញាប់ញ័រនៃចិត្តនោះ ដូច្នេះឯង ។

ក្នុងកាលចប់គាថា ព្រះមេឃិយត្ថេរៈបានតាំងនៅក្នុងព្រះសោតាបត្តិ-ផល ។ ជនសូម្បីពួកដទៃដ៏ច្រើន ក៏បានជាអរិយបុគ្គល មានសោតាបត្តិផលជាដើមនោះឯង ។

ចប់ រឿងមេឃិយត្ថេរៈទី ១

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.033_att